ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ចូល ស.អ.យ/ផក
លេខ: ០៥០
ថ្ងៃទី៣១ ខែ1 ឆ្នាំ20

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ: ០០១ ស.អ.យ.ស.ណ.ន

ថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២០

# សេចក្ដីណែនាំ
## ស្ដីពី
## ការអនុវត្តវិធានការបង្ការជំងឺឆ្លងរលាកសួតបង្កឡើងដោយមេរោគកូរ៉ូណាថ្មី (2019-nCoV) នៅតាមមណ្ឌល មជ្ឈមណ្ឌល សមាគម សហគមន៍ និងអង្គការជាតិ អន្តរជាតិ

បច្ចុប្បន្ននេះ វីរុសកូរ៉ូណាប្រភេទថ្មី(2019-nCoV) បាន និងកំពុងរាតត្បាតយ៉ាងខ្លាំងនៅទីក្រុង វូហាន ខេត្តហ៊ូបេ សាធារណរដ្ឋប្រជាមានិតចិន ហើយបានរាតត្បាតដល់បណ្ដាប្រទេសផ្សេងៗទៀតនៅជុំវិញពិភពលោក ដោយមិនទាន់មានថ្នាំព្យាបាល ឬវ៉ាក់សាំងបង្ការនៅឡើយ។

ក្នុងគោលបំណងដើម្បីចូលរួមចំណែកក្នុងការបង្ការ និងទប់ស្កាត់ជំងឺនេះ ស្របតាមសេចក្ដីអំពាវនាវរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបន្ថែមលើខ្លឹមសារនៃសេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមជម្រាបជូនលោក លោកស្រី ប្រធានមណ្ឌល មជ្ឈមណ្ឌល សមាគម សហគមន៍ អង្គការជាតិ និងអន្តរជាតិទាំងអស់ ដែលកំពុងផ្ដល់សេវាសង្គមកិច្ចដល់ជនរងគ្រោះ និងជនងាយរងគ្រោះ ពិសេសកុមារ ស្ត្រី មនុស្សវ័យចាស់ ជនចាស់ជរា ជនពិការ និងជនវិបល្លាសស្មារតី ត្រូវអនុវត្តនូវវិធានការដូចខាងក្រោម ៖

១. មិនត្រូវប៉ះពាល់ដោយផ្ទាល់ និងនៅឱ្យឆ្ងាយពីអ្នកមានជំងឺផ្លូវដង្ហើមស្រួចស្រាល់ ដែលមានអាការដូចជា គ្រុនក្ដៅ ក្អក កណ្ដាស់ ផ្ដាស់សាយ ហូរសំបោរ ឈឺបំពង់ក ដង្ហើមខ្លី ពិបាកដកដង្ហើម ឬមានរោគសញ្ញាណាមួយគួរឱ្យកត់សម្គាល់ខុសពីប្រក្រតី។

២. មិនត្រូវខាក ឬស្ដោះនៅតាមទីធ្លាសាធារណៈ ពិសេសកន្លែងរស់នៅ និងស្នាក់នៅ។

៣. ត្រូវយកចិត្តទុកដាក់លាងដៃឱ្យបានទៀងទាត់ និងញឹកញាប់ជាមួយសាប៊ូ និងទឹកស្អាត ជាពិសេសបន្ទាប់ពីមានការប៉ះពាល់ផ្ទាល់ជាមួយអ្នកជំងឺ ឬបរិស្ថានជុំវិញ។

៤. ត្រូវប្រកាន់ភ្ជាប់នូវការអនុវត្តអនាម័យស្អាត និងសុវត្ថិភាពម្ហូបអាហារជាប្រចាំ ដោយពិសារអាហារដែលចម្អិនឆ្អិនល្អ ជាពិសេសសាច់ និងស៊ុត។ ចំពោះអ្នកចម្អិនអាហារត្រូវប្រើប្រាស់ជ្រុញ និងកាំបិតផ្សេងគ្នាសម្រាប់អាហារឆៅ និងអាហារឆ្អិន និងត្រូវលាងដៃនៅចន្លោះពេលកាន់អាហារឆៅ និងអាហារឆ្អិន។

៥. ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការថែរក្សាអនាម័យកន្លែងរស់នៅ អាគារស្នាក់នៅ អាហារដ្ឋាន កន្លែងលេងកំសាន្ត កន្លែងហាត់ប្រាណ និងកន្លែងផ្ដល់សេវាកម្មផ្សេងៗ។

៦. ត្រូវធ្វើការហាមឃាត់ជនរងគ្រោះ និងជនងាយរងគ្រោះ ដែលកំពុងស្ថិត នៅក្រោមការទទួលខុសត្រូវរបស់ខ្លួន ទៅកន្លែងលក់ដូរសត្វរស់ កសិដ្ឋានចិញ្ចឹមសត្វ សត្តឃាតដ្ឋាន និងប៉ះពាល់ជាមួយសត្វព្រៃ ឬសត្វដែលគេសង្ស័យថាមានវីរុសកំពុងចរាចរ។



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ,ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦ ០៨១/២៣ ៧២៦ ១០៣
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 725 081 / 23 726 103

៧. ត្រូវធ្វើការតាមដានជាប្រចាំនូវសុខភាពរបស់កុមារ ស្ត្រី ជនពិការ មនុស្សវ័យចាស់ និងជនចាស់ជរា ដែលកំពុងស្នាក់នៅ ឬការទទួលខុសត្រូវរបស់ស្ថាប័នខ្លួន ក្នុងករណីមានរោគសញ្ញាណាមួយដែលមានការសង្ស័យដូចទៅនឹងរោគសញ្ញានៃប្រភេទមេរោគថ្មីនេះ អ្នកទទួលខុសត្រូវរបស់ស្ថាប័ននោះត្រូវរាយការណ៍ជាបន្ទាន់ទៅក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាល (តាមរយៈលេខទូរសព្ទទាន់ហេតុការណ៍ ១១៥) ដើម្បីចាត់វិធានការបន្តក្នុងការទុកដាក់អ្នកជំងឺ។

៨. ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីផលប៉ះពាល់ ដែលបណ្តាលមកពីជំងឺរលាកសួតបង្កឡើងដោយវីរុសកូរ៉ូណាប្រភេទថ្មី(2019-nCoV) នៅតាមស្ថាប័នរបស់ខ្លួនតាមការណែនាំរបស់ក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាល។

៩. ត្រូវសហការត្រៀមរៀបចំក្នុងការដោះស្រាយឆ្លើយតបទៅតាមគោលដៅបានទាន់ពេលវេលា ។

នាយកដ្ឋានជំនាញពាក់ព័ន្ធ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្តទាំងអស់ ត្រូវរាយការណ៍ព័ត៌មានអំពីផលប៉ះពាល់ ដែលបណ្តាលមកពីជំងឺរលាកសួតបង្កឡើងដោយវីរុសកូរ៉ូណាប្រភេទថ្មី (nCoV2019) ផ្ញើមកនាយកដ្ឋានសុខុមាលភាពសង្គម ដើម្បីធ្វើរបាយការណ៍បូកសរុប និងរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងពីបញ្ហាប្រឈម និងការដោះស្រាយក្នុងការឆ្លើយតបជូនជនរងគ្រោះបានទាន់ពេលវេលា ។

នាយកដ្ឋានសុខុមាលភាពសង្គម នៃអគ្គនាយកដ្ឋានបច្ចេកទេស ត្រូវធ្វើការតាមដាន និងស្រង់ទិន្នន័យជនរងគ្រោះ និងងាយរងគ្រោះ ដែលទទួលរងផលប៉ះពាល់ដោយសារជំងឺរលាកសួតដែលបង្កឡើងដោយវីរុសកូរ៉ូណាប្រភេទថ្មី(nCoV2019)នេះ ជាប្រចាំនៅតាមបណ្តារាជធានី ខេត្ត (ពិសេសខេត្តដែលមានច្រកជាប់ព្រំដែន) ដែលងាយទទួលរងផលប៉ះពាល់ដោយសារវីរុសខាងលើ។

ទទួលបានសេចក្តីណែនាំនេះ សូមអគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានជំនាញពាក់ព័ន្ធ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្តទាំងអស់ ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់មណ្ឌល មជ្ឈមណ្ឌល សមាគម សហគមន៍ អង្គការជាតិ និងអន្តរជាតិទាំងអស់ ដែលកំពុងផ្តល់សេវាសង្គមកិច្ចដល់ជនរងគ្រោះ ពិសេសកុមារ ស្ត្រី មនុស្សវ័យចាស់ ជនចាស់ជរា ជនពិការ និងជនវិបល្លាសស្មារតី អនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ។

រដ្ឋមន្ត្រី

**វង សូត**

**ចម្លងជូន:**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ
- ឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានបច្ចេកទេស

«ដើម្បីជូនជ្រាប»

- នាយកដ្ឋានជំនាញពាក់ព័ន្ធ
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ទាំង២៥
- មណ្ឌល មជ្ឈមណ្ឌល សហគមន៍ សមាគម អង្គការជាតិ អន្តរជាតិ

«ដើម្បីអនុវត្ត»

- ឯកសារ-កាលប្បវត្តិ
- ឯកសារ-កាលប្បវត្តិ